**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ:....០០៣/២០....គ.ម.ក./ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានចុះបញ្ជីលក់មូលបត្រកម្ចីបំណុល របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
Phone : 855-23-885-611
E-mail : info@secc.gov.kh
Fax : 855-23-885-622
Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០១៦/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុល របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំអនុម័តលើវិសោធនកម្មនៃវិធានចុះបញ្ជីលក់មូលបត្របំណុល របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩។

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ១៨ ថ្មី, ប្រការ១៩ ថ្មី និងប្រការ២០ ថ្មី នៃវិធានចុះបញ្ជីលក់មូលបត្របំណុល របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ១៨, ប្រការ១៩ និងប្រការ២០ នៃវិធានចុះបញ្ជីលក់មូលបត្របំណុល របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០១៦/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្របំណុល របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច លោកជំទាវ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ..០០៣/[illegible]/ប្រ.ក

ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

ស្តីពី

## ការកែប្រែវិធានចុះបញ្ជីលក់មូលបត្របំណុល
## របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

---

**ប្រការ១៨ ថ្មី.- ថ្លៃសេវាសម្រាប់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុល**

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវា ផ.ម.ក. លើការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្របំណុលចំនួន ៤.០០០.០០០ (បួនលាន) រៀល នៅពេលដាក់ពាក្យស្នើសុំ។

**ប្រការ១៩ ថ្មី.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុល**

បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីមូលបត្របំណុល ដោយផ្អែកលើទំហំមូលបត្របំណុលដែលចុះបញ្ជី ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម÷

| ទំហំមូលបត្របំណុលដែលចុះបញ្ជីសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ២០.០០០.០០០.០០០ ៛ | ៣.០០០.០០០ ៛ |
| ពី | ២០.០០០.០០០.០០១ ៛ | ដល់ | ៤០.០០០.០០០.០០០ ៛ | ០,០២៥% |
| ពី | ៤០.០០០.០០០.០០១ ៛ | ដល់ | ៨០.០០០.០០០.០០០ ៛ | ០,០១៥% |
| ពី | ៨០.០០០.០០០.០០១ ៛ | ដល់ | ១២០.០០០.០០០.០០០ ៛ | ០,០១០% |
| | | លើសពី | ១២០.០០០.០០០.០០០ ៛ | ០,០០៥% |

ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុលសរុបមិនត្រូវលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀលឡើយ និងត្រូវបង់មុនថ្ងៃចុះបញ្ជីជាផ្លូវការ។

**ប្រការ២០ ថ្មី.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុលប្រចាំឆ្នាំ**

បុគ្គលចុះបញ្ជីលក់មូលបត្របំណុលត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំ ដោយផ្អែកលើទំហំមូលបត្របំណុល ដែលចុះបញ្ជី ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម÷

| ទំហំមូលបត្របំណុលដែលចុះបញ្ជីសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០ ៛ | ដល់ | ២០.០០០.០០០.០០០ ៛ | ១.០០០.០០០ ៛ |
| ពី | ២០.០០០.០០០.០០១ ៛ | ដល់ | ៤០.០០០.០០០.០០០ ៛ | ០,០១៥% |
| ពី | ៤០.០០០.០០០.០០១ ៛ | ដល់ | ៨០.០០០.០០០.០០០ ៛ | ០,០១០% |
| ពី | ៨០.០០០.០០០.០០១ ៛ | ដល់ | ១២០.០០០.០០០.០០០ ៛ | ០,០០៥% |
| | | លើសពី | ១២០.០០០.០០០.០០០ ៛ | ០,០០២៥% |

ថ្លៃសេវាចុះបញ្ជីលក់មូលបត្របំណុលប្រចាំឆ្នាំសរុបមិនត្រូវលើសពី១០.០០០.០០០ (ដប់លាន) រៀល និងត្រូវបង់យ៉ាងយូររយៈពេល ៣០ (សាមសិប) ថ្ងៃ ក្រោយពេលចុះបញ្ជីលក់មូលបត្របំណុលជាផ្លូវការ និង សម្រាប់ឆ្នាំបន្តបន្ទាប់ ត្រូវបង់យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែមករា ជារៀងរាល់ឆ្នាំ ។

* * *